22140565

International Baccalaureate®
Baccalauréat International
Bachillerato Internacional

**KHMER A: LITERATURE – HIGHER LEVEL – PAPER 1**
**KHMER A : LITTÉRATURE – NIVEAU SUPÉRIEUR – ÉPREUVE 1**
**KHMER A: LITERATURA – NIVEL SUPERIOR – PRUEBA 1**

Friday 9 May 2014 (morning)
Vendredi 9 mai 2014 (matin)
Viernes 9 de mayo de 2014 (mañana)

2 hours / 2 heures / 2 horas

---

INSTRUCTIONS TO CANDIDATES

- Do not open this examination paper until instructed to do so.
- Write a literary commentary on one passage only.
- The maximum mark for this examination paper is *[20 marks]*.

INSTRUCTIONS DESTINÉES AUX CANDIDATS

- N'ouvrez pas cette épreuve avant d'y être autorisé(e).
- Rédigez un commentaire littéraire sur un seul des passages.
- Le nombre maximum de points pour cette épreuve d'examen est *[20 points]*.

INSTRUCCIONES PARA LOS ALUMNOS

- No abra esta prueba hasta que se lo autoricen.
- Escriba un comentario literario sobre un solo pasaje.
- La puntuación máxima para esta prueba de examen es *[20 puntos]*.


© International Baccalaureate Organization 2014

https://xtremepape.rs/

*សូមអ្នកសរសេរអត្ថាធិប្បាយបែបអក្សរសិល្ប៍ទៅលើអត្ថបទ**មួយ** ក្នុងចំណោមអត្ថបទខាងក្រោមនេះ៖*

**1.**

ថ្ងៃនេះជាថ្ងៃបុណ្យភ្ជុំបិណ្ឌ ប្រពៃណីជាតិរបស់ខ្មែរដ៏ធំ ដែលប្រជាជនខ្មែរប្រារព្ធឡើងជារៀងរាល់ឆ្នាំ។ ទាំងមន្ត្រីរាជការ អង្គការសង្គមស៊ីវិលទាំងឡាយបានសំរាកគ្រប់ៗគ្នា។ នៅក្នុងគេហដ្ឋានដ៏ប្រណិតរបស់ម៉ាក់តារា មានគន្ធា និង តារា កំពុងតែតុបតែងកាយយ៉ាងស្អាតបាត ហើយគន្ធា ថ្ងៃនេះពិតជាស្អាតណាស់, ទោះស្ថិតក្នុងសំលៀកបំពាក់សាមញ្ញសំពត់ហូ្បីបអាវសធម្មតាក៏ដោយ ក៏សម្ផស្សរបស់តូចតន់ស្អាតប្រៀបបាននឹងទេពអប្សរចុះពីឋានសួគ៌ា ធ្វើអោយយុវកំលោះតារាលួចសំលឹងនាងដោយឥតព្រិចភ្នែក ហើយបានចាប់ចិត្តប្រតិព័ទ្ធចំពោះនាងខ្លាំងឡើងៗ តែនរៈជាមនុស្សមានចំណេះដឹងជ្រៅជ្រះ ស្គាល់ខុសស្គាល់ត្រូវ ស្គាល់ពីគុណធម៌ក្នុងសង្គម តែទោះជាមនុស្សម្នាក់មានចិត្តរឹងយ៉ាងណាក៏ដោយ ក៏មិនអាចយកឈ្នះលើ សេចក្ដីស្នេហាបានឡើយ។ ចំណែកឯនាយកំលោះដ៏ស្រស់សង្ហារបស់យើងវិញ ក៏មិនអន់ប៉ុន្មានដែរ រហូតធ្វើឱ្យមាណវីលួចសរសើរក្នុងចិត្តមិនតិចទេ, នរៈបានដើរទៅជិតមាណវី ហើយសំលឹងតាំងពីលើដល់ក្រោម ហើយពោលថា :

-គន្ធា ថ្ងៃនេះស្អាតណាស់ !

-ចាស៎,... អរគុណអ្នកប្រុស !

នរៈរកបន្តប្រយោគទៅទៀត តែត្រូវម្ដាយរបស់គេចេញមកដល់ហើយនិយាយទៅកាន់គន្ធាតូចតន់ដ៏ច្រឡឹងនេះ

-គន្ធា ចូលទៅយកបាយសម្លមួយស្រាក់ទៀតមក !...

-ចាស៎, អ៊ុំស្រី !

វាចាចប់តូចតន់បានធ្វើដំណើរទៅកន្លែងចំអិនអាហារក្នុងដំណើរល្វតល្វន់ដូចទេពអប្សរ... ធ្វើឱ្យនរៈយើងអនេត្រាតាមសំលឹងនាងឥតឈប់ ដែលម៉ាក់របស់គេនៅទីនោះ មានការសង្ស័យ តែគាត់ពុំជឿថាបុត្ររបស់គាត់តែមួយនេះ ទៅស្រលាញ់អ្នកបំរើខ្លួនឡើយ...

រំពេចនោះ, គន្ធា តូចតន់ដ៏ច្រឡឹងនេះ ចេញមកវិញដោយមានក្រមាពានាផង, ដៃម្ខាងយួរស្រាក់ ហើយដៃម្ខាងទៀតកាន់ថាសនំ... តារាឃើញដូចនោះ ក៏ដើរចូលទៅកាន់មាណវី ដោយលូកដៃទៅចាប់ថាសនំហើយវាចា :

-មកឱ្យខ្ញុំជួយកាន់ថាសនេះមួយ !...

-មិនបាច់ទេ, អ្នកប្រុស !...

នរ : លូកដៃទៅកាន់ថាសនំហើយទាញមក តែគន្ធា ពុំព្រមរួចទាញវិញបន្តិច ថាសនំក៏ធ្លាក់ចុះមកក្រោម ធ្វើអោយកំពប់នំអស់, ឃើញដូច្នេះម៉ាក់តារា ក៏ស្រែកឡើង...

-គន្ធាម៉េច ក៏ប្រហែសខ្លាំងម្លេះ កំពប់នំអស់ហើយ ! តើបានអ្វីយកទៅប្រគេនព្រះសង្ឃ ?...

-ចា៎ស់,... អោយខ្ញុំសុំទោស, អ៊ុំស្រី !...



https://xtremepape.rs/

-អើ...ស្អីអាងសុំទោស...សុំទោសតែរហូត...ស្រីកញ្ជើផ្ទុះ...

-មាណវីពុំចេញស្តីអ្វីទាំងអស់ បានត្រឹមតែឱនមុខចុះ សំរក់ទឹកនេត្រា នរៈឃើញក៏បាននិយាយទៅកាន់ម៉ាក់របស់គេ...

-ឈប់ខឹងទៅម៉ាក់, ការពិតកំហុសរបស់កូនទេ ហើយនំ ក៏ពុំខូចខាតអ្វីដែរ យើងរើសដាក់វិញតែនំទទឹកទៅ ចំណែកនំចិនយើងនៅសល់ទៀតតើ !...

-មិនកើតទេកូន ! ...ហ៊ឹះមកតែមីស្អីគេហ្នឹង! ធ្វើអ្វីមិនប្រយ័ត្នទេ...បើយកទៅប្រគេនលោកយ៉ាងនេះវាមិនបានបុណ្យទេ ហើយថែមទាំងបាបផង។

-មិនមែនទេម៉ាក់, គ្រាន់តែធ្លាក់ប៉ុណ្ណេះ មិនជាអ្វីឡើយ សំខាន់របស់អ្វីក៏ដោយ យើងប្រគេនលោក ឬឱ្យទានគេ ឱ្យតែមានចិត្តសទ្ធាជ្រះថ្លាពិតជាបានបុណ្យ ផ្ទុយទៅវិញនោះរបស់ល្អ ថ្លៃៗ ឆ្ងាញ់ យ៉ាងណាក៏ដោយ បើធ្វើពុំដោយចិត្តជ្រះថ្លា ចិត្តក្តៅក្រហាយនោះ ពុំបានបុណ្យឡើយណាម៉ាក់។

ម៉ាក់តារា ហាក់ត្រជាក់ចិត្តបន្តិច ពេលលឺហេតុផលកូននិយាយដូច្នេះ ហើយក៏វាចា :

-បានហើយ ៗ ! ម៉ាក់ និយាយពុំឈ្នះកូនឡើយ... គន្ធានាងឯងនៅធ្មឹងដល់ណាទៀត ? ទៅយកចាសថ្មីមកដាក់នំ ហើយយកចាសនេះទៅលាងទុកហើយជូតសំអាតផង។

-ចាស៎!... អ៊ំ... ស្រី ! (និយាយរដាក់រដុប)

នារីកំសត់ក្រោក ហើយធ្វើដំណើរដោយដៃកាន់ចាសទៅលាងយ៉ាងប្រញាប់... ក្នុងចិត្តបុប្ផាម្នាក់នេះ ពិតជាពុំមានការតូចចិត្តឬខឹងចំពោះម៉ាក់តារាឡើយ តែនាងយំតូចចិត្តនឹងវាសនាអកុសលរបស់ខ្លួនដែលមានឪពុកមិនច្រលំនឹងគេ ហើយបានដំណឹងថា សព្វថ្ងៃនេះ រស់នៅភ្នំពេញ ពុំបានមករកសួរនាំប្រពន្ធកូនរស់នៅទីណាឡើយ។

បន្តិចក្រោយមកនារីកំសត់ ប្រកបដោយទឹកមុខស្រពោនចេញមក ប៉ុន្តែទោះបីជាភ័ក្ត្រតូចគន់ម្នាក់នេះស្រពោនយ៉ាងណា ក៏សម្រស់របស់នាងមិនថយចុះឡើយ ឃើញដូច្នេះ ម៉ាក់តារា ក៏និយាយទៅកាន់កូនប្រុសរបស់ខ្លួន...

-យី ! តារា ម៉េចក៏ក្រឃើញលោកសម្បត្តិ មកដល់ម្លេះ ? (និយាយដោយអើតមើលផ្លូវ...)

-កូនមិនដឹងដែរម៉ាក់... ចាំបន្តិចទៀតទៅម៉ាក់...

-អើ... ចាំក៏ចាំអញ្ចឹង ! ព្រោះនៅព្រឹកដែរ...

រំពេចនោះ សម្លេងស៊ីផ្លេក៏បន្លឺឡើងនៅមុខគេហដ្ឋានដ៏ប្រណិតនេះ... ម៉ាក់នរៈ ស្ទុះអើតមើលឃើញជាក់ថាជារថយន្តរបស់លោកសម្បត្តិ ក៏និយាយឡើង :

-តោះ, តារា កូនចេញឡានយើងទៅ អនាគតប៉ាក្មេកកូនមកដល់ហើយ...

-បាទម៉ាក់ ! កុំនិយាយប៉ាក្មេកស្អីភ្លាមនោះ...

-អើ !... រៀនហៅឱ្យហើយទៅកូន...

យីន លាងគង់, *ថ្ងៃរះពីទិសខាងលិច* (២០០២)



https://xtremepape.rs/

**2.**

អ្នកជាម៉ែឪតែងនៅនៃបនិត្យ        ចង់ឃើញកូនពិតតាំងពីក្នុងផ្ទៃ
ផែនការជិវិតគិតជាប់មមៃ        មុននឹងកូនថ្ងៃប្រសូតចាកគត៌        ។
ដ្បិតជាកូនហើយអ្នកណាមិនគិត        ចង់បានកូនពិតប្រកបដោយធម៌
ពេលកូនកើតមកខំប្រឹងបីព        បើបានកូនល្អម៉ែឪអរណាស់        ។
តែកូនទាំងឡាយមានបីប្រភេទ        ចូរចាំសង្កេតពិនិត្យឱ្យច្បាស់
ដូចដូងមួយផ្លាយមានតក់មាននាឡិខ្លះ        កម្មរៀបប្តូរផ្លាស់តាមបុណ្យម៉ែឪ        ។
ទីមួយគឺជាអតិជាតបុត្រ        កូនល្អបំផុតចេះដឹងខុសត្រូវ
មានសិលខ្ពង់ខ្ពស់លើសពីម៉ែឪ        រស់ឥតអាស្រូវជួយដល់ឪម៉ែ        ។
ទីពីគឺជាអនុជាតបុត្រ        មានសិលបរិសុទ្ធស្មើឪម៉ែដែរ
អាចអប់រំបានមិនលំបាកថែ        មិនឱ្យឪម៉ែទុក្ខសោកសង្រេង        ។
ទីបីគឺជាអវជាតបុត្រ        ខិលខូចបំផុតតាំងតែពីក្មេង
អប់រំពុំបានពិបាកក្រៃលែង        ម៉ែឪវង្វេងព្រោះកូនតិរិច្ឆាន        ។
តើបុណ្យម៉ែត្រូវជួបកូនណា        កូនបីប្រការម៉ែឪគង់បាន
ជួបកូនណាមួយឥតបីខកខាន        សូមតាំងសន្តានឱ្យបានមាំទាំ        ។
បើបានកូនល្អក៏ត្រេកអរចុះ        បើបានកូនខុសក៏ត្រូវខិតខំ
កុំអស់សង្ឃឹមក្នុងការដឹកនាំ        អប់រំផ្សេងៗតាមតួនាទី        ។
ត្រូវចែកវិជ្ជាជាកេរដល់កូន        គុណឥតសាបសូន្យម៉ែឪទាំងពីរ
កូនមានកតញ្ញូតវេទី        ដល់លោកទាំងពីរបានសុខសិរី        ។
ព្រះគុណម៉ែឪសែនធ្ងន់ពេកក្រៃ        ពុំអាចកាត់ថ្លៃធ្ងន់លើសផែនដី
គ្រប់គ្រងរក្សាកូនទាំងប្រុសស្រី        ដោយចិត្តមេត្រីប្រណីប្រណិត        ។
កូនណាភ្លាំងភ្លាត់ភ្លេចគុណម៉ែឪ        បាបធ្ងន់ធ្លាក់ជ្រៅក្នុងភពងងឹត
បើមិនព្រមកែប្រែចិត្តគំនិត        ដូចអស់ជីវិតសល់តែរាងកាយ        ។
ពេលអស់បុណ្យចាស់ស្លាប់ផ្លាស់ជាតិថ្មី        នរកអវីចីហួសក្តីបរិយាយ
ព្រោះតែវង្វេងភ្លេចឪពុកម្តាយ        ធ្លាក់ទៅអបាយពុំងាយរួចបាន        ។
ចំណែកកូនដែលដឹងគុណម៉ែឪ        គឺដើរត្រូវផ្លូវឆ្ពោះទៅសួគ៌ឋាន
រស់នៅមានន័យប្រពៃថ្កើងថ្កាន        ស្លាប់ទៅក៏បានសោយសុគតិភព        ។

គុយ សុធន, *ប្រជុំកំនាព្យ* (១០១)



https://xtremepape.rs/